# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ :......១៦៣.......ក.ប/ប្រ.ក

# ប្រកាស
## ស្តីពី
## ទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុក

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ២៤៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញគោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥ ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៥
- តាមការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១**.-

ប្រកាសនេះមានគោលបំណងបង្កើតឲ្យមាន និងគ្រប់គ្រងលើទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុក។

**ប្រការ២**.-

ប្រកាសនេះមានគោលដៅអនុញ្ញាតឲ្យ ទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុក ជ្រើសរើសកម្លាំងពលកម្ម បណ្តុះបណ្តាលណែនាំតម្រង់ទិសការងារនិងវិជ្ជាជីវៈ និងដាក់ឲ្យធ្វើការ ។

**ប្រការ៣**.-

ក-ប្រកាសនេះអនុវត្តចំពោះទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុកទាំងអស់។

ខ-ប្រកាសនេះអនុវត្តចំពោះសកម្មភាពសេដ្ឋកិច្ចគ្រប់ប្រភេទ រួមទាំងការងារផ្ទះ លើកលែងតែប្រភេទការងារផ្សេងទៀត ដែលត្រូវបានហាមឃាត់ដោយបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

គ-ប្រកាសនេះបង្កើតឲ្យមានដំណើរការនៃទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុក ក្នុងការផ្តល់សេវាគ្រប់គ្រាន់ក្នុងដំណើរការរៀបចំឲ្យអ្នករកការងារធ្វើទទួលបានការងារធ្វើ ក៏ដូចជាការការពារអ្នកប្រើប្រាស់សេវាទាំងឡាយ នៃទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុក។

**ប្រការ៤**.-

ទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុកសំដៅដល់នីតិបុគ្គលឯកជនដែលផ្តល់សេវានានានៃទីផ្សារការងារដូចខាងក្រោម៖

-ផ្គូរផ្គងធ្វើឲ្យត្រូវគ្នារវាងទីកន្លែងការងារដែលទំនេរ និងអ្នកដែលរកការងារធ្វើ ដោយទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុក មិនមែនជាភាគីមួយនៃទំនាក់ទំនងវិជ្ជាជីវៈ រវាងកម្មករនិយោជិត និងនិយោជកនោះទេ។

-នាំអ្នករកការងារធ្វើឲ្យបានជួបភាគីទី៣ ជារូបវន្តបុគ្គល ឬនីតិបុគ្គល ដែលជាអ្នកចាត់ចែងការងារឲ្យធ្វើ និងជាអ្នកគ្រប់គ្រងការងារនោះ។

-ផ្តល់សេវាផ្សេងទៀតក្នុងការរកការងារឲ្យធ្វើ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀតជាធរមាន។

ការគ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួនរបស់អ្នករកការងារធ្វើ សំដៅដល់ការប្រមូល ការរក្សាទុក ការរៀបចំចាត់ចែង ការផ្តល់ដំណឹង ឬការប្រើប្រាស់ព័ត៌មានផ្សេងៗទៀតទាក់ទងដល់អ្នករកការងារធ្វើ ដើម្បីកត់ត្រាអត្តសញ្ញាណ ឬ សម្គាល់អត្តសញ្ញាណ។

**ប្រការ៥**.-

ទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុកត្រូវរក្សាព័ត៌មាន និងឯកសារផ្ទាល់ខ្លួនរបស់អ្នករកការងារធ្វើទុកជាការសម្ងាត់លើកលែងតែមានការស្នើសុំពីស្ថាប័នមានសមត្ថកិច្ច។

ដោយឡែកសម្រាប់គោលបំណងប្រមូលចងក្រង និងផ្សព្វផ្សាយជាសាធារណៈនូវស្ថិតិ និងព័ត៌មានទីផ្សារការងារ សំដៅលើកកំពស់ប្រសិទ្ធភាពយន្តការទីផ្សារការងារទាំងមូល និងដើម្បីគ្រប់គ្រងព័ត៌មានទីផ្សារការងារ ទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុក មានកាតព្វកិច្ចផ្តល់ព័ត៌មាន និងទិន្នន័យស្តីពីព័ត៌មានជ្រើសរើសកំលាំងពលកម្ម និងអ្នកស្វែងរកការងារធ្វើ ដែលទទួលបានការងារ ក្នុងពេលកន្លងមក បច្ចុប្បន្ន និងទៅ

អនាគត តាមប្រភេទមុខរបរ និងសកម្មភាពសេដ្ឋកិច្ចជាប្រចាំតាមទម្រង់ដែលបានកំណត់ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងទីភ្នាក់ងារជាតិមុខរបរ និងការងារ។

**ប្រការ៦**.-

នីតិបុគ្គលឯកជនដែលមានបំណងធ្វើជា ទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុក ត្រូវបំពេញបែបបទស្នើសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ដើម្បីស្នើសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុក នីតិបុគ្គលឯកជននីមួយៗ ត្រូវតែបំពេញឲ្យបានគ្រប់លក្ខខណ្ឌ កំណត់ដូចខាងក្រោម៖

-ត្រូវមានលក្ខន្តិកៈក្រុមហ៊ុន និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ដែលចេញដោយក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា។

-ត្រូវមានឯកសារសម្គាល់អត្តសញ្ញាណ និងឯកសារបញ្ជាក់ទីលំនៅនៃម្ចាស់ក្រុមហ៊ុន ឬម្ចាស់ភាគហ៊ុនសំខាន់បំផុត និងនាយកគ្រប់គ្រង ដែលចេញឲ្យដោយអាជ្ញាធរមូលដ្ឋានដែលខ្លួនកំពុងរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

-ត្រូវមានទីតាំងសមស្របសម្រាប់ដំណើរការប្រឹក្សាយោបល់ ការបង្ហាត់បង្ហាញ និងការណែនាំតម្រង់ទិសអំពីការងារជូនអ្នករកការងារធ្វើ។

-ត្រូវមានការបញ្ជាក់អំពីការទទួលបានការបណ្តុះបណ្តាលជំនាញមូលដ្ឋាន អំពីច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនិងវិស័យការងារ និងសម្ភារៈបរិក្ខាសមស្របសម្រាប់ដំណើរការ។

-ត្រូវមានកិច្ចសន្យារវាងទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុក ជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ៧**.-

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពិនិត្យ និងសម្រេចចេញប្រកាសអនុញ្ញាតជូននីតិបុគ្គលឯកជននីមួយៗ ធ្វើជាទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុក ដែលមានសុពលភាពរយៈពេលប្រាំ(៥)ឆ្នាំ។ ការចេញប្រកាសអនុញ្ញាតនឹងធ្វើឡើងក្នុងរយៈពេលមិនលើសពីសាមសិប(៣០)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលពាក្យស្នើសុំ និងសំណុំឯកសារគ្រប់គ្រាន់។

ក្នុងករណីបន្តសុពលភាពនៃប្រកាសអនុញ្ញាតឲ្យធ្វើជាទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុក សាមីនីតិបុគ្គល ត្រូវធ្វើសំណើសុំបន្តសុពលភាពប្រកាសអនុញ្ញាតនេះ ក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ មុនកាលបរិច្ឆេទផុតសុពលភាព។ ប្រកាសអនុញ្ញាតថ្មីនេះមានសុពលភាពរយៈពេលប្រាំ(៥)ឆ្នាំ។

**ប្រការ៨**.-

ក្នុងការទទួលបានប្រកាសអនុញ្ញាតឲ្យធ្វើជាទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុកជាលើកដំបូងនិងក្នុងករណីទទួលបានការបន្តសុពលភាពប្រកាសអនុញ្ញាតឲ្យធ្វើ

ជាទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុកមួយលើកៗ សាមីនីតិបុគ្គលឯកជននីមួយៗជាប់កាតព្វកិច្ចបង់កម្រៃសេវាសាធារណៈជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមបទប្បញ្ញត្តិដោយឡែក។

**ប្រការ៩**.-

ក្នុងដំណើរការផ្តល់សេវារកការងារឲ្យធ្វើនេះ ទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុកត្រូវជូនដំណឹងដល់អាជ្ញាធរមូលដ្ឋាន។

**ប្រការ១០**.-

ទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុក ត្រូវផ្តល់របាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ទាក់ទងដល់លទ្ធផលការងាររបស់ខ្លួន ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំពោះទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុកដែលស្ថិតនៅរាជធានីភ្នំពេញ និងជូនមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ចំពោះទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុកដែលស្ថិតនៅតាមបណ្តាខេត្ត។

**ប្រការ១១**.-

ទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុកនីមួយៗត្រូវរក្សាទុករាល់ឯកសារទាំងឡាយ ទាក់ទងដល់ការផ្តល់សេវានានាក្នុងការរកការងារធ្វើជូនអ្នកដាក់ពាក្យរកការងារធ្វើ ដែលបានប្រើប្រាស់សេវារបស់សាមីទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុកនីមួយៗ ក្នុងរយៈពេល៥(ប្រាំ)ឆ្នាំ សម្រាប់ការប្រើប្រាស់តាមសេចក្តីត្រូវការចាំបាច់ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ និងបទបញ្ញាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ១២**.-

ទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុកទាំងឡាយណា ដែលផ្តល់សេវានានា មានលក្ខណៈជាការផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុកត្រូវជាប់កាតព្វកិច្ចស្ថិតនៅក្រោមបទប្បញ្ញត្តិនៃប្រកាសនេះ។ជនណាដែលធ្វើសកម្មភាពក្នុងការផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុកដោយគ្មានប្រកាសអនុញ្ញាតរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬប្រកាសអនុញ្ញាត ដែលផុតសុពលភាពត្រូវទទួលការដាក់ពិន័យទៅតាមបទប្បញ្ញត្តិជាធរមាន។

**ប្រការ១៣**.-

ទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុកនីមួយៗ ដែលទទួលបានការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវដំណើរការផ្តល់សេវារកការងារជូនពលរដ្ឋធ្វើឲ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិនៃប្រកាសនេះ និងបទប្បញ្ញត្តិច្បាប់ និងបទបញ្ញាជាធរមានដែលជាប់ទាក់ទង។

ក្នុងករណីពិនិត្យឃើញថា មានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ហើយដែលជាបទល្មើសមានចែងក្នុងច្បាប់និងបទបញ្ញានានាទីភ្នាក់ងារឯកជនផ្តល់សេវារកការងារ

ឲ្យធ្វើក្នុងស្រុកនីមួយៗនោះ នឹងត្រូវដកហូតឬលុបចោល ការអនុញ្ញាតនិងចោទប្រកាន់ទៅតាមនីតិវិធីច្បាប់ជាធរមាន។

**ប្រការ១៤**.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គាធិការនៃអគ្គាធិការដ្ឋាន អង្គភាពក្រោមចំណុះក្រសួង និងទីភ្នាក់ងារជាតិមុខរបរ និងការងារ និងទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឲ្យធ្វើក្នុងស្រុក ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
-គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
-ដូចប្រការ១៤
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ